# ច្បាប់

# ស្តីពី

# ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

បច្ចុប្បន្នភាព ខែកញ្ញា ឆ្នាំ២០២១

# ច្បាប់
# ស្តីពី
# ការបោះឆ្នោតជ្រើសតាំង
# សមាជិកព្រឹទ្ធសភា

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលដៅកំណត់ការរៀបចំបែបបទ និងការប្រព្រឹត្តទៅនៃការចាត់តាំង និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងការកំណត់អំពីអ្នកបោះឆ្នោតអង្គបោះឆ្នោត និងមណ្ឌលបោះឆ្នោត។

**មាត្រា ២.-**

ការគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៣.-ថ្មី**

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវធ្វើឡើង ០៦ (ប្រាំមួយ) ឆ្នាំម្តង នៅថ្ងៃអាទិត្យ សប្តាហ៍ទី៤ យ៉ាងយូរមុនដំណាច់ឆ្នាំទី៦ នៃនីតិកាលព្រឹទ្ធសភា លើកលែងតែក្នុងករណីដែលមានចែងក្នុងបទប្បញ្ញត្តិមាត្រា ១០២ថ្មី នៃរដ្ឋធម្មនុញ្ញ ។

កាលបរិច្ឆេទនៃការបោះឆ្នោត ត្រូវកំណត់ និងប្រកាសដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

នីតិកាលព្រឹទ្ធសភា ត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។

## ជំពូកទី២
## ចំនួនសមាជិកព្រឹទ្ធសភា ប្រព័ន្ធបោះឆ្នោត មណ្ឌលបោះឆ្នោត និងការកំណត់ចំនួនអាសនៈ

**មាត្រា ៤..**

ព្រឹទ្ធសភា មានចំនួនសមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៥..**

សមាជិកព្រឹទ្ធសភាចំនួន ២(ពីរ)រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ ។

**មាត្រា ៦..**

សមាជិកព្រឹទ្ធសភាចំនួន ២(ពីរ)រូប ត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយប្រៀប ។

**មាត្រា ៧..**

សមាជិកព្រឹទ្ធសភាឯទៀត ត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកល មិនចំពោះ តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

**មាត្រា ៨.-**

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រ និងការបែងចែកអាសនៈតាមមណ្ឌលត្រូវធ្វើតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ដូចមានកំណត់ក្នុងមាត្រា១៣៥ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

**មាត្រា ៩.-**

មណ្ឌលបោះឆ្នោត ត្រូវរៀបចំ និងបែងចែកជា ៨(ប្រាំបី) ភូមិភាគ ។

អាសនៈនៅក្នុងព្រឹទ្ធសភា ដែលត្រូវបោះឆ្នោតជ្រើសតាំងត្រូវកំណត់ត្រឹមចំនួន ៥៨ (ហាសិបប្រាំបី) ដោយបែងចែកតាមភូមិភាគ ដូចខាងក្រោម ៖

- ភូមិភាគទី១ រាជធានីភ្នំពេញ មាន៦ (ប្រាំមួយ)អាសនៈ
- ភូមិភាគទី២ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ មាន ៨ (ប្រាំបី) អាសនៈ
- ភូមិភាគទី៣ ខេត្តកណ្តាល មាន៥ (ប្រាំ) អាសនៈ
- ភូមិភាគទី៤ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ និងខេត្ត

ប៉ៃលិន មាន១០ (ដប់) អាសនៈ

- ភូមិភាគទី៥ ខេត្តតាកែវ ខេត្តកំពត និងខេត្តកែប មាន៧ (ប្រាំពីរ) អាសនៈ
- ភូមិភាគទី៦ ខេត្តព្រៃវែង និងខេត្តស្វាយរៀង មាន៧ (ប្រាំពីរ) អាសនៈ
- ភូមិភាគទី៧ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តកោះកុង និងខេត្តព្រះសីហនុ មាន ៩ (ប្រាំបួន) អាសនៈ
- ភូមិភាគទី៨ ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី មាន ៦ (ប្រាំមួយ) អាសនៈ ។

## ជំពូកទី៣
## អ្នកបោះឆ្នោត អង្គបោះឆ្នោត បញ្ជីបោះឆ្នោត និងការិយាល័យបោះឆ្នោត

**មាត្រា ១០..**

អ្នកបោះឆ្នោត និងអង្គបោះឆ្នោត គឺជាតំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងតំណែង នៅក្នុងក្របខ័ណ្ឌនៃភូមិភាគនីមួយៗ ។

**មាត្រា ១១..**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំបញ្ជីបោះឆ្នោត និងផ្តល់សុពលភាពលើបញ្ជីនេះយ៉ាងតិច ១៥ (ដប់ប្រាំ)ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

បញ្ជីបោះឆ្នោត ដែលត្រូវបានផ្តល់សុពលភាពហើយ មិនអាចកែប្រែបានទេ លើកលែងតែមានអ្នកបោះឆ្នោតណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនោះទទួលមរណភាព ។

ក្នុងករណី មានសមាជិកណាម្នាក់នៃអង្គបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ទទួលមរណភាព ស្ថាប័នមានសមត្ថកិច្ច ត្រូវបំពេញបែបបទផ្លាស់ប្តូរសមាជិកអង្គបោះឆ្នោតនោះ ក្នុងរយៈពេល០៧ (ប្រាំពីរ) ថ្ងៃយ៉ាងតិចមុនថ្ងៃបោះឆ្នោត

ដើម្បីឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដាក់ជំនួស
ក្នុងបញ្ជីបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បិទផ្សាយបញ្ជីបោះឆ្នោតដំបូងយ៉ាងតិច ២៨ (សែសិបប្រាំបី)ថ្ងៃមុនថ្ងៃបោះឆ្នោត នៅទីប្រជុំជនរាជធានី ខេត្ត ។

ដើម្បីបោះឆ្នោតបាន អ្នកមានសិទ្ធិបោះឆ្នោត ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

-មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

-មានឈ្មោះក្នុងបញ្ជីបោះឆ្នោត

-មិនត្រូវស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬមិនត្រូវបានដកសិទ្ធិបោះឆ្នោត

-ពុំមែនជាជនវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលទូទៅ ដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

**មាត្រា ១២..**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំការិយាល័យបោះឆ្នោត ការិយាល័យរាប់សន្លឹកឆ្នោតនៅទីប្រជុំជនរាជធានី ខេត្ត នីមួយៗ ។

## ជំពូកទី៤
## ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ

**មាត្រា ១៣**..

មាត្រា២៣ ២៤ ២៥ ២៦ ២៧ ២៨ ២៩ ៣០ ៣១ ៣២ ៣៣ ៣៤ ៣៥ ៣៦ និងមាត្រា៣៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តចំពោះការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ប៉ុន្តែបេក្ខជននេះ ត្រូវមានអាយុយ៉ាងតិច ៤០ (សែសិប)ឆ្នាំ ។

**មាត្រា ១៤**..

គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ត្រូវធ្វើបញ្ជីរាយនាមបេក្ខជនពេញសិទ្ធិស្មើនឹងចំនួនអាសនៈនៃភូមិភាគទីមួយៗ និងបេក្ខជនបម្រុងមានចំនួនស្មើនឹងបេក្ខជនពេញសិទ្ធិរៀបតាមលំដាប់លេខរៀង ដូចជាការរៀបចំបញ្ជីបេក្ខជនតំណាងរាស្ត្រដែរ ។

**មាត្រា ១៥ ..**

បទបញ្ញា និងនីតិវិធីទាំងឡាយ ស្តីពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## ជំពូកទី៥
## ការឃោសនាបោះឆ្នោត

**មាត្រា ១៦..**

ការឃោសនាបោះឆ្នោត មានទិសដៅឱ្យបេក្ខជន និងគណបក្សនយោបាយ ដែលបានចុះបញ្ជីធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនជូនដល់អ្នកបោះឆ្នោត ។

**មាត្រា ១៧..**

ការឃោសនាបោះឆ្នោត ត្រូវធ្វើនៅតាមមណ្ឌលភូមិភាគនីមួយៗ ។

យុទ្ធនាការឃោសនាបោះឆ្នោត មានរយៈពេល១៤ (ដប់បួន)ថ្ងៃ ហើយគ្រប់សកម្មភាពឃោសនាបោះឆ្នោតត្រូវចប់ ២៤ (ម្ភៃបួន) ម៉ោងមុនថ្ងៃបោះឆ្នោត ។

**មាត្រា ១៨.-**

មាត្រា៦៨ ៦៩ ៧០ ៧១ កថាខ័ណ្ឌទី២ នៃមាត្រា៧២ មាត្រា៧៣ ៧៤ ៧៥ ៧៦ ៧៧ ៧៨ ៧៩ ៨០ ៨១ ៨២ ៨៣ ៨៤ ៨៥ ៨៦ ៨៧ ៨៨ ៨៩ ៩០ និងមាត្រា៩១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការឃោសនាបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ដោយឡែក ចំពោះការរៀបចំក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ នៅក្នុងមណ្ឌលភូមិភាគនីមួយៗ ត្រូវកំណត់យ៉ាងច្រើន ០២ (ពីរ) ដង ក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។

# ជំពូកទី៦
# ភ្នាក់ងារគណបក្សនយោបាយ
# និងអ្នកសង្កេតការណ៍បោះឆ្នោត

**មាត្រា ១៩..**

គណបក្សនយោបាយនីមួយៗ ដែលឈរឈ្មោះបោះឆ្នោតមានសិទ្ធិចាត់តាំងតំណាងរបស់ខ្លួន ២(ពីរ)រូប ពេញសិទ្ធិ ១(មួយ)រូប និងបម្រុង ១(មួយ)រូប ដើម្បីចូលរួមសង្កេតការណ៍មើលការបោះឆ្នោតតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ ។

សិទ្ធិ តួនាទី និងលក្ខខណ្ឌផ្សេងៗ ក្នុងការស្នើសុំជាភ្នាក់ងារគណបក្សនយោបាយ ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ២០..**

មាត្រា ១០ ១១ ១២ ១៣ ១៤ ១៥ ១៦ ១៧ ១៨ ១៩ ២០ ២១ និងមាត្រា២២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការសង្កេតការណ៍នៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

## ជំពូកទី៧
## ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត

**មាត្រា ២១..**

*ការបោះឆ្នោតត្រូវធ្វើតែ ១(មួយ)ថ្ងៃ ។*

*ការបោះឆ្នោតប្រព្រឹត្តទៅចាប់ពីម៉ោង ៧ :០០( ប្រាំពីរ ) ព្រឹក រហូតដល់ម៉ោង១៥ :០០( ដប់ប្រាំ ) លើកលែងតែមានសេចក្តីសម្រេចផ្សេងពីនេះ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។*

*ប្រសិនបើអ្នកបោះឆ្នោតទាំងអស់ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត បានបោះគ្រប់គ្នាហើយ គណៈកម្មការការិយាល័យបោះឆ្នោត អាចប្រកាសបញ្ចប់ការបោះឆ្នោតមុនម៉ោង១៥ :០០ ( ដប់ប្រាំ ) ។*

*ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវបិទការបោះឆ្នោតនៅម៉ោង ១៥ :០០ ( ដប់ប្រាំ ) ។*

*ជនគ្រប់រូបដែលមានបំណងបោះឆ្នោត មិនត្រូវអនុញ្ញាតឱ្យចូលក្នុងបរិវេណខាងក្នុងក្រោយម៉ោង១៥ :០០ ( ដប់ប្រាំ ) ឡើយ ។*

ជនដែលមានសិទ្ធិបោះឆ្នោត ក្រោយម៉ោង១៥:០០ ( ដប់ប្រាំ ) ហើយអាចអនុញ្ញាតឱ្យបោះឆ្នោត គឺជាជនដែលស្ថិតក្នុងការិយាល័យបោះឆ្នោត ឬក្នុងបរិវេណខាងក្នុងនៅម៉ោង ១៥:០០( ដប់ប្រាំ ) ។

**មាត្រា ២២..**

គណៈកម្មការការិយាល័យបោះឆ្នោត ត្រូវទទួលខុសត្រូវរាប់សន្លឹកឆ្នោតនៅទីកន្លែង ក្រោយការប្រកាសបញ្ចប់ការបោះឆ្នោត ។

**មាត្រា ២៣..**

គណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ត្រូវបញ្ជូនកំណត់ហេតុសរុបលទ្ធផលនៃការបោះឆ្នោតនៅក្នុងរាជធានី ខេត្តរបស់ខ្លួន ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីបូកសរុបលទ្ធផលតាមភូមិភាគនីមួយៗ ។

**មាត្រា ២៤..**

មាត្រាទាំងឡាយ ដែលមានចែងក្នុងជំពូកទី៨ អំពីការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត លើកលែងតែមាត្រា៩២ ១០៣ ១១៦ ១២៣ ១២៦ និងមាត្រា១២៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាង

រាស្ត្រ និងបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវយកមកអនុវត្តក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

## ជំពូកទី៨
## សមត្ថកិច្ចដោះស្រាយករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោត

**មាត្រា ២៥.-**

គណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ជាអ្នកសម្រេចដំបូងបង្អស់លើករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា លើកលែងករណីវិវាទកម្មទាំងឡាយដែលជាសមត្ថកិច្ចដំបូងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងក្រុមប្រឹក្សាធម្មនុញ្ញ ។

ក្នុងករណីមានបណ្តឹងជំទាស់ ឬតវ៉ានឹងសេចក្តីសម្រេចរបស់គណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសមត្ថកិច្ចពិនិត្យ និងសម្រេច ។

**មាត្រា ២៦..**

ក្នុងករណីមានបណ្ដឹងជំទាស់ ឬតវ៉ានឹងសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចសម្រេចចុងក្រោយបិទផ្លូវតវ៉ា លើករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

**មាត្រា ២៧..**

នីតិវិធីដោះស្រាយការវិវាទ ដែលមានចែងក្នុងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការដោះស្រាយករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ការរាប់ចំនួនថ្ងៃតវ៉ា និងការសម្រេចលើបណ្ដឹងជំទាស់ ឬតវ៉ា ពុំត្រូវបានរាប់បញ្ចូលថ្ងៃបុណ្យជាផ្លូវការ ។

## ជំពូកទី៩
## ការបាត់បង់អាសនៈនៃព្រឹទ្ធសភា និងការជ្រើសតាំងសមាជិកជំនួស

**មាត្រា ២៨.-**

មាត្រា១៣៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តចំពោះការបាត់បង់អាសនៈនៃព្រឹទ្ធសភា ។

**មាត្រា ២៩.-**

សមាជិកព្រឹទ្ធសភា ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ទៅតាមករណីណាមួយដូចខាងក្រោម ៖

-សាមីខ្លួនទទួលមរណភាព

-សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច

-សាមីខ្លួនសុំលាឈប់ជាលាយលក្ខណ៍អក្សរ ពីសមាជិកព្រឹទ្ធសភា

-សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារ ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ

-សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្ស
នយោបាយរបស់ខ្លួន ។

កាលបើសមាជិកព្រឹទ្ធសភាណាមួយ ត្រូវបាត់បង់សមាជិកភាពមានរយៈពេល ០៦(ប្រាំមួយ)ខែ យ៉ាងតិចមុនចប់នីតិកាលស្ថាប័នដែលមានអាសនៈនៅព្រឹទ្ធសភា ឬសាមីគណបក្សនយោបាយនោះ អាចស្នើចាត់តាំង ឬជ្រើសតាំងសមាជិកថ្មី ឬជ្រើសរើសក្នុងចំណោមបេក្ខជន ដែលមានឈ្មោះតាមលំដាប់លេខរៀងក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត នៃមណ្ឌលបោះឆ្នោតរបស់សាមីខ្លួននោះ មកជំនួសដោយមិនបាច់បោះឆ្នោតឡើងវិញ ។

## ជំពូកទី១០
## ទោសប្បញ្ញត្តិ

**មាត្រា ៣០..**

ជំពូកស្តីពីទោសប្បញ្ញត្តិ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

## ជំពូកទី១១
## អវសានប្បញ្ញត្តិ

**មាត្រា ៣១..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ និងត្រូវជំនួសដោយច្បាប់នេះ ។

**មាត្រា ៣២..**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

# កំណត់សម្គាល់

# កំណត់សម្គាល់

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៥/០២០ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៥ ត្រូវបាននិរាករណ៍ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៦ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ។

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៦ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧នេះ ត្រូវបានធ្វើវិសោធនកម្មចំនួនមួយលើកគឺ **មាត្រា ៣..ថ្មី** ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខនស/រកម/១០១៧/ ០១១ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

ដើម្បីសម្រួលដល់ការសិក្សា ក៏ដូចជាការបង្កភាពងាយស្រួលក្នុងការអានច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះពុម្ពនេះ មានរៀបចំភ្ជាប់ជាមួយនូវ ៖

១-ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ឆ្នាំ២០០៥។

២-ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ឆ្នាំ២០១៧។

៣-ច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ឆ្នាំ២០១៧។

៤-សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្តីពីការពិនិត្យធម្មនុញ្ញភាពច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

# ព្រះរាជក្រម

នស/រកម/០៦០៥/០២០

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ៣ និងព្រឹទ្ធសភា បានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ព្រមទាំងក្រុមប្រឹក្សាធម្មនុញ្ញ បានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញតាមសេចក្តីសម្រេចលេខ ០៧០/០០២/២០០៥/កបធ.ច ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់ការរៀបចំបែបបទនិងការប្រព្រឹត្តទៅនៃការតាំង និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងការកំណត់អំពីអ្នកបោះឆ្នោត អង្គបោះឆ្នោតនិងមណ្ឌលបោះឆ្នោត ។

**មាត្រា ២.-**

ព្រឹទ្ធសភាមានចំនួនសមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្ដាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៣.-**

នីតិកាលរបស់ព្រឹទ្ធសភាមានកំណត់ ៦ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។

**មាត្រា ៤.-**

សមាជិកព្រឹទ្ធសភាចំនួន ០២ រូប ត្រូវបានតាំងដោយព្រះមហាក្សត្រ ។

**មាត្រា ៥.-**

សមាជិកព្រឹទ្ធសភាចំនួន ០២ រូប ត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយប្រៀប ។

**មាត្រា ៦.-**

សមាជិកព្រឹទ្ធសភាឯទៀត ត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកលមិនចំពោះ តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

## ជំពូកទី ២

## ប្រព័ន្ធបោះឆ្នោត មណ្ឌលបោះឆ្នោត ការបែងចែកអាសនៈ អ្នកបោះឆ្នោត អង្គបោះឆ្នោត បញ្ជីអ្នកបោះឆ្នោត និងការិយាល័យបោះឆ្នោត

**មាត្រា ៧.-**

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាត្រូវធ្វើឡើង ៦ (ប្រាំមួយ) ឆ្នាំម្តង នៅថ្ងៃអាទិត្យសប្តាហ៍ទី ៨ មុនដំណាច់ឆ្នាំទី ៦ នៃនីតិកាលព្រឹទ្ធសភា លើកលែងតែក្នុងករណីដែលមានចែងក្នុងបទប្បញ្ញត្តិមាត្រា ១០២ថ្មី នៃរដ្ឋធម្មនុញ្ញ ។

**មាត្រា ៨.-**

ការបោះឆ្នោតត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រ និងការបែងចែកអាសនៈតាមមណ្ឌល ត្រូវធ្វើតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ដូចមានកំណត់ក្នុងមាត្រា ១១៨ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

**មាត្រា ៩.-**

មណ្ឌលបោះឆ្នោតត្រូវរៀបចំជាភូមិភាគដែលមានតារាងកំណត់ដូចខាងក្រោម :

- ភូមិភាគទី ១ ក្រុងភ្នំពេញ
- ភូមិភាគទី ២ ខេត្តកំពង់ចាម
- ភូមិភាគទី ៣ ខេត្តកណ្តាល
- ភូមិភាគទី ៤ ខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងក្រុងប៉ៃលិន
- ភូមិភាគទី ៥ ខេត្តតាកែវ កំពត និងក្រុងកែប
- ភូមិភាគទី ៦ ខេត្តព្រៃវែង និងស្វាយរៀង
- ភូមិភាគទី ៧ ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ កោះកុង និងក្រុងព្រះសីហនុ
- ភូមិភាគទី ៨ ខេត្តកំពង់ធំ ព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី

មាត្រា ១០.-

០៦ ខែយ៉ាងតិចមុនចប់នីតិកាល ព្រឹទ្ធសភាត្រូវអនុម័តកំណត់ចំនួនអាសនៈនិងការបែងចែកអាសនៈ តាមភូមិភាគនីមួយៗសម្រាប់នីតិកាលបន្ទាប់ ហើយត្រូវផ្សព្វផ្សាយជាសាធារណៈ ។

ក្នុងករណីឧកខានពុំបានកំណត់ជាថ្មីនូវអាសនៈក្នុងព្រឹទ្ធសភា ចំនួនអាសនៈតាមភូមិភាគនោះ ត្រូវយកតាមចំនួនអាសនៈក្នុងព្រឹទ្ធសភាដែលមានក្នុងនីតិកាលចុងក្រោយ ។

មាត្រា ១១.-

អ្នកបោះឆ្នោត និងអង្គបោះឆ្នោតគឺតំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ទាំងអស់ក្នុងតំណែង នៅក្នុងក្របខ័ណ្ឌនៃភូមិភាគនីមួយៗ ។

មាត្រា ១២.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរៀបចំបញ្ជីអ្នកបោះឆ្នោត និងផ្តល់សុពលភាពលើបញ្ជីនេះយ៉ាងតិច ១៥ថ្ងៃ មុនថ្ងៃបោះឆ្នោត ។ បញ្ជីអ្នកបោះឆ្នោត ដែលត្រូវបានផ្តល់សុពលភាពហើយមិនអាចកែប្រែបានទេ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបិទផ្សាយបញ្ជីឈ្មោះអ្នកបោះឆ្នោតដំបូងយ៉ាងតិច ៤៨ (សែសិបប្រាំបី) ថ្ងៃ មុនថ្ងៃបោះឆ្នោត នៅទីប្រជុំជនខេត្ត-ក្រុង ។

មាត្រា ១៣.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរៀបចំការិយាល័យបោះឆ្នោតការិយាល័យរាប់សន្លឹកឆ្នោតនៅទីប្រជុំជនខេត្ត-ក្រុងនីមួយៗ ។

## ជំពូកទី ៣

## ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និង បញ្ជីបេក្ខជនឈរឈ្មោះ

មាត្រា ១៤.-

ការបើកបញ្ជីចុះឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ត្រូវចាប់ផ្តើម ៩០(កៅសិប) ថ្ងៃមុនថ្ងៃបោះឆ្នោត ។

មាត្រា ១៥.-

គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ត្រូវធ្វើបញ្ជីរាយនាមបេក្ខជនពេញសិទ្ធិស្មើនឹងចំនួនអាសនៈនៃភូមិភាគនីមួយៗ និងបេក្ខជនបម្រុងមានចំនួនស្មើនឹងបេក្ខជនពេញសិទ្ធិរៀបតាមលំដាប់លេខរៀងដូចជាការរៀបចំបញ្ជីបេក្ខជនតំណាងរាស្ត្រដែរ ។

មាត្រា ១៦.-

បែបបទ លក្ខខណ្ឌនិងនីតិវិធីទាំងឡាយស្តីពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

## ជំពូកទី ៤

## បេក្ខជនសមាជិកព្រឹទ្ធសភា

មាត្រា ១៧.-

មាត្រា៣៣ថ្មី ៣៤ថ្មី ៣៥ថ្មី ៣៦ថ្មី ៣៧ថ្មី ៣៨ថ្មីនិងមាត្រា៣៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦-១២-១៩៩៧ និងព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧-០៩-២០០២ ត្រូវយកមកអនុវត្តចំពោះបេក្ខជនសមាជិកព្រឹទ្ធសភា ប៉ុន្តែបេក្ខជននេះត្រូវមានអាយុយ៉ាងតិច ៤០ (សែសិប) ឆ្នាំ ។

## ជំពូកទី ៥

## ការឃោសនាបោះឆ្នោត

មាត្រា ១៨.-

ការឃោសនាបោះឆ្នោតមានទិសដៅឱ្យបេក្ខជន និងគណបក្សនយោបាយដែលបានចុះបញ្ជីធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយនិងកម្មវិធីនយោបាយរបស់ខ្លួនជូនដល់អ្នកបោះឆ្នោត ។

**មាត្រា ១៩.-**

យុទ្ធនាការឃោសនាបោះឆ្នោតមានរយៈពេល ២១ (ម្ភៃមួយ) ថ្ងៃ ហើយគ្រប់សកម្មភាពឃោសនាបោះឆ្នោតត្រូវចប់ ២៤ (ម្ភៃបួន) ម៉ោង មុនថ្ងៃបោះឆ្នោត ។

**មាត្រា ២០.-**

មាត្រា ៧១ ៧៣ ៧៤ ៧៥ ៧៦ ៧៧ ៨០ ៨១ ៨២ និងមាត្រា ៨៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការឃោសនាបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

## ជំពូកទី ៦
## អំណាចគណបក្សនយោបាយ និងអ្នកសង្កេតការណ៍

**មាត្រា ២១.-**

មាត្រា ២៦ថ្មី ២៧ ២៨ និងមាត្រា ២៩ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការសង្កេតការណ៍នៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

## ជំពូកទី ៧
## ការគ្រប់គ្រងការបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និង ការបូកសរុបលទ្ធផលនៃការបោះឆ្នោត

**មាត្រា ២២.-**

ការគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ២៣.-**

តាមរយៈក្របខ័ណ្ឌនៃអំណាចដែលមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចកំណត់បទបញ្ជា និង

នីតិវិធីពាក់ព័ន្ធនឹងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាបន្ថែមលើភារកិច្ចបច្ចុប្បន្ននេះ ។

**មាត្រា ២៤.-**

ការបោះឆ្នោតត្រូវធ្វើតែមួយថ្ងៃ ។

ការបោះឆ្នោតប្រព្រឹត្តទៅចាប់ពីម៉ោង ៧:០០ (ប្រាំពីរ) ព្រឹករហូតដល់ម៉ោង ១៥:០០ (ដប់ប្រាំ) លើកលែងតែមានសេចក្តីសម្រេចផ្សេងពីនេះរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ប្រសិនបើអ្នកបោះឆ្នោតទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានបោះគ្រប់គ្នាហើយ គណៈកម្មការការិយាល័យបោះឆ្នោតអាចប្រកាសបញ្ចប់ការបោះឆ្នោតមុនម៉ោង ១៥:០០ (ដប់ប្រាំ) ។

ប្រធានការិយាល័យបោះឆ្នោត ត្រូវប្រកាសបិទការបោះឆ្នោតនៅម៉ោង ១៥:០០ (ដប់ប្រាំ) ។

ជនគ្រប់រូបដែលមានបំណងបោះឆ្នោតមិនត្រូវអនុញ្ញាតឱ្យចូលក្នុងបរិវេណខាងក្នុងក្រោយម៉ោង ១៥:០០ (ដប់ប្រាំ) ឡើយ ។

ជនដែលមានសិទ្ធិបោះឆ្នោតក្រោយម៉ោង ១៥:០០ (ដប់ប្រាំ) ហើយអាចអនុញ្ញាតឱ្យបោះឆ្នោតគឺជាជនដែលស្ថិតក្នុងការិយាល័យបោះឆ្នោត ឬក្នុងបរិវេណខាងក្នុងនៅម៉ោង ១៥:០០ (ដប់ប្រាំ) ។

**មាត្រា ២៥.-**

គណៈកម្មការការិយាល័យបោះឆ្នោត ត្រូវទទួលខុសត្រូវរាប់សន្លឹកឆ្នោតនៅនឹងកន្លែងក្រោយការប្រកាសបញ្ចប់ការបោះឆ្នោត ។

**មាត្រា ២៦.-**

គណៈកម្មការខេត្ត-ក្រុងរៀបចំការបោះឆ្នោត ត្រូវបញ្ជូនកំណត់ហេតុសរុបលទ្ធផលនៃការបោះឆ្នោតនៅក្នុងខេត្ត-ក្រុងរបស់ខ្លួនទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីបូកសរុបលទ្ធផលតាមភូមិភាគនីមួយៗ ។

**មាត្រា ២៧.-**

បែបបទ នីតិវិធីផ្សេងៗទៀតនៃការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតដែលមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

## ជំពូកទី ៨

## សមត្ថកិច្ចដោះស្រាយការវិវាទ ស្តីពីការបោះឆ្នោតជ្រើសតាំង សមាជិកព្រឹទ្ធសភា

**មាត្រា ២៨.-**

គណៈកម្មការខេត្ត-ក្រុងរៀបចំការបោះឆ្នោតជាអ្នកសម្រេចដំបូងបង្អស់លើការវិវាទទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ក្នុងករណីមានបណ្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់គណៈកម្មការខេត្ត-ក្រុងរៀបចំការបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសមត្ថកិច្ចពិនិត្យនិងសម្រេច ។

**មាត្រា ២៩.-**

ក្នុងករណីមានបណ្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចសម្រេចចុងក្រោយបិទផ្លូវតវ៉ាលើការវិវាទទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

**មាត្រា ៣០.-**

នីតិវិធីដោះស្រាយការវិវាទដែលមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការដោះស្រាយការវិវាទស្តីពីការបោះឆ្នោតជ្រើស

តាំងសមាជិកព្រឹទ្ធសភា ។

ការរាប់ចំនួនថ្ងៃតវ៉ានិងការសម្រេចលើបណ្តឹងតវ៉ា ពុំត្រូវបានរាប់បញ្ចូលថ្ងៃបុណ្យជាផ្លូវការ ។

## ជំពូកទី ៩
## ករណីជ្រើសតាំងជំនួសសមាជិកព្រឹទ្ធសភា

**មាត្រា ៣១.–**

សមាជិកព្រឹទ្ធសភាត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយដូចខាងក្រោម :

- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច
- សាមីខ្លួនសុំលាឈប់ជាលាយលក្ខណ៍អក្សរពីសមាជិកព្រឹទ្ធសភា
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬ បទមជ្ឈិមណាមួយ
- សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន

កាលបើសមាជិកព្រឹទ្ធសភាណាមួយត្រូវបាត់បង់សមាជិកភាព មានរយៈពេល ៦ (ប្រាំមួយ)ខែ យ៉ាងតិចមុនចប់នីតិកាល សាមីគណបក្សនយោបាយនោះអាចស្នើជ្រើសតាំងសមាជិកថ្មីជំនួសដោយជ្រើសរើសក្នុងចំណោមបេក្ខជនដែលមានឈ្មោះតាមលំដាប់លេខរៀងក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃមណ្ឌលបោះឆ្នោតរបស់សាមីខ្លួននោះមកជំនួស ដោយមិនបាច់បោះឆ្នោតឡើងវិញ ។

## ជំពូកទី ១០
## ទទិកា

**មាត្រា ៣២.-**

មាត្រា ១២១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រូវយកមកអនុវត្តក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

## ជំពូកទី ១១
## ទោសប្បញ្ញត្តិ

**មាត្រា ៣៣.-**

មាត្រា ១២៤ថ្មី ១២៥ថ្មី ១២៦ថ្មី ១២៧ថ្មី ១២៨ថ្មី ១២៩ថ្មី ១៣០ថ្មី ១៣១ និង មាត្រា ១៣៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

## ជំពូកទី ១២
## អន្តរប្បញ្ញត្តិ

**មាត្រា ៣៤.-**

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាសិរាប់នីតិកាលទី ២ នៃព្រឹទ្ធសភាត្រូវប្រព្រឹត្តទៅនាថ្ងៃអាទិត្យ ទី ២២ ខែ មករា ឆ្នាំ ២០០៦ ។

**មាត្រា ៣៥.-**

ក្រោយពីច្បាប់នេះចូលជាធរមាន ដើម្បីការបោះឆ្នោតនៅថ្ងៃអាទិត្យ ទី ២២ ខែ មករា ឆ្នាំ ២០០៦ ចំនួនអាសនៈនៃព្រឹទ្ធសភាដែលត្រូវបោះឆ្នោតជ្រើសតាំងត្រូវកំណត់ត្រឹម ៥៧(ហាសិបប្រាំពីរ) ។ ចំនួនអាសនៈតាមភូមិភាគមានដូចខាងក្រោម :

| | | |
|---|---|---|
| -ភូមិភាគទី ១ | ក្រុងភ្នំពេញ | មាន ៦ អាសនៈ |
| -ភូមិភាគទី ២ | ខេត្តកំពង់ចាម | មាន ៨ អាសនៈ |
| -ភូមិភាគទី ៣ | ខេត្តកណ្តាល | មាន ៥ អាសនៈ |

-ភូមិភាគទី ៤ ខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងក្រុងប៉ៃលិន មាន១០ អាសនៈ

-ភូមិភាគទី ៥ ខេត្តតាកែវ កំពត និងក្រុងកែប មាន ៧ អាសនៈ

-ភូមិភាគទី ៦ ខេត្តព្រៃវែង និងស្វាយរៀង មាន ៧ អាសនៈ

-ភូមិភាគទី ៧ ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ពោធិសាត់ កោះកុង និងក្រុងព្រះសីហនុ មាន ៨ អាសនៈ

-ភូមិភាគទី ៨ ខេត្តកំពង់ធំ ព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី មាន ៦ អាសនៈ

ចំនួនអាសនៈនេះត្រូវផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់ ។

## ជំពូកទី ១៣

## អវសានប្បញ្ញត្តិ

**មាត្រា ៣៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៧.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៥

នស/រកម.០៥០៦.៣០០

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសំខាន់**

**ប្រមុខរដ្ឋស្តីទី**

**ឯកឧត្តមលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ: ៧/៥០ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[illegible] តាន់

# ព្រះរាជក្រម

នស/រកម/០៧១៧/០០៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៨ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៨៦/០២៦/២០១៧ កបធ.ប ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៧ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ច្បាប់
# ស្ដីពី
# ការបោះឆ្នោតជ្រើសតាំង
# សមាជិកព្រឹទ្ធសភា

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលដៅកំណត់ការរៀបចំបែបបទ និងការប្រព្រឹត្តទៅនៃការចាត់តាំង និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងការកំណត់អំពីអ្នកបោះឆ្នោត អង្គបោះឆ្នោត និងមណ្ឌលបោះឆ្នោត ។

**មាត្រា ២.-**

ការគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៣.-**

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវធ្វើឡើង ០៦ (ប្រាំមួយ) ឆ្នាំម្តង នៅថ្ងៃអាទិត្យ សប្តាហ៍ទី ៨ មុនដំណាច់ឆ្នាំទី ៦ នៃនីតិកាលព្រឹទ្ធសភា លើកលែងតែក្នុងករណីដែលមានចែងក្នុងបទប្បញ្ញត្តិមាត្រា ១០២ ថ្មី នៃរដ្ឋធម្មនុញ្ញ ។

កាលបរិច្ឆេទនៃការបោះឆ្នោត ត្រូវកំណត់ និងប្រកាសដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

នីតិកាលព្រឹទ្ធសភា ត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។

## ជំពូកទី ២
## ចំនួនសមាជិកព្រឹទ្ធសភា ប្រព័ន្ធបោះឆ្នោត មណ្ឌលបោះឆ្នោត និងការកំណត់ចំនួនអាសនៈ

**មាត្រា ៤.-**

ព្រឹទ្ធសភា មានចំនួនសមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៥.-**

សមាជិកព្រឹទ្ធសភាចំនួន ២(ពីរ) រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ ។

**មាត្រា ៦.-**

សមាជិកព្រឹទ្ធសភាចំនួន ២(ពីរ) រូប ត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយ

**មាត្រា ៧.‒**

សមាជិកព្រឹទ្ធសភាឯទៀត ត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកល មិនចំពោះតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

**មាត្រា ៨.‒**

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រ និងការបែងចែកអាសនៈតាមមណ្ឌល ត្រូវធ្វើតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ដូចមានកំណត់ក្នុងមាត្រា ១៣៥ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

**មាត្រា ៩.‒**

មណ្ឌលបោះឆ្នោត ត្រូវរៀបចំ និងបែងចែកជា ៨(ប្រាំបី) ភូមិភាគ ។

អាសនៈនៅក្នុងព្រឹទ្ធសភាដែលត្រូវបោះឆ្នោតជ្រើសតាំង ត្រូវកំណត់ត្រឹមចំនួន ៥៨ (ហាសិបប្រាំបី ) ដោយបែងចែកតាមភូមិភាគ ដូចខាងក្រោម ៖

| | |
|---|---|
| -ភូមិភាគទី ១ រាជធានីភ្នំពេញ | មាន ៦ (ប្រាំមួយ) អាសនៈ |
| -ភូមិភាគទី ២ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ | មាន ៨ (ប្រាំបី) អាសនៈ |
| -ភូមិភាគទី ៣ ខេត្តកណ្តាល | មាន ៥ (ប្រាំ) អាសនៈ |
| -ភូមិភាគទី ៤ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ និងខេត្តប៉ៃលិន | មាន ១០ (ដប់) អាសនៈ |
| -ភូមិភាគទី ៥ ខេត្តតាកែវ ខេត្តកំពត និងខេត្តកែប | មាន ៧ (ប្រាំពីរ) អាសនៈ |
| -ភូមិភាគទី ៦ ខេត្តព្រៃវែង និងខេត្តស្វាយរៀង | មាន ៧ (ប្រាំពីរ) អាសនៈ |
| -ភូមិភាគទី ៧ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តកោះកុង និងខេត្តព្រះសីហនុ | មាន ៩ (ប្រាំបួន) អាសនៈ |
| -ភូមិភាគទី ៨ ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី | មាន ៦ (ប្រាំមួយ) អាសនៈ ។ |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ជំពូកទី ៣
## អ្នកបោះឆ្នោត អង្គបោះឆ្នោត បញ្ជីបោះឆ្នោត
## និងការិយាល័យបោះឆ្នោត

**មាត្រា ១០.-**

អ្នកបោះឆ្នោត និងអង្គបោះឆ្នោត គឺជាតំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងតំណែង នៅក្នុងក្របខ័ណ្ឌនៃភូមិភាគនីមួយៗ ។

**មាត្រា ១១.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំបញ្ជីបោះឆ្នោត និងផ្តល់សុពលភាពលើបញ្ជីនេះយ៉ាងតិច ១៥ (ដប់ប្រាំ) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

បញ្ជីបោះឆ្នោត ដែលត្រូវបានផ្តល់សុពលភាពហើយ មិនអាចកែប្រែបានទេ លើកលែងតែមានអ្នកបោះឆ្នោតណាម្នាក់ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនោះទទួលមរណភាព ។

ក្នុងករណី មានសមាជិកណាម្នាក់នៃអង្គបោះឆ្នោត ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតទទួលមរណភាព ស្ថាប័នមានសមត្ថកិច្ច ត្រូវបំពេញបែបបទផ្លាស់ប្តូរសមាជិកអង្គបោះឆ្នោតនោះ ក្នុងរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃ យ៉ាងតិចមុនថ្ងៃបោះឆ្នោត ដើម្បីឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដាក់ជំនួសក្នុងបញ្ជីបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បិទផ្សាយបញ្ជីបោះឆ្នោតដំបូងយ៉ាងតិច ៤៨ (សែសិបប្រាំបី) ថ្ងៃ មុនថ្ងៃបោះឆ្នោត នៅទីប្រជុំជនរាជធានី ខេត្ត ។

ដើម្បីបោះឆ្នោតបាន អ្នកមានសិទ្ធិបោះឆ្នោត ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

-មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

-មានឈ្មោះក្នុងបញ្ជីបោះឆ្នោត

-មិនត្រូវស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬមិនត្រូវបានដកសិទ្ធិបោះឆ្នោត

-ពុំមែនជាជនវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលទូទៅ ដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

**មាត្រា ១២.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំការិយាល័យបោះឆ្នោត ការិយាល័យរាប់សន្លឹកឆ្នោតនៅទីប្រជុំជនរាជធានី ខេត្ត នីមួយៗ ។



# ជំពូកទី ៤

## ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ

**មាត្រា ១៣.–**

មាត្រា២៣ ២៤ ២៥ ២៦ ២៧ ២៨ ២៩ ៣០ ៣១ ៣២ ៣៣ ៣៤ ៣៥ ៣៦ និងមាត្រា៣៧ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តចំពោះការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ប៉ុន្តែបេក្ខជននេះ ត្រូវមានអាយុយ៉ាងតិច ៤០ (សែសិប) ឆ្នាំ ។

**មាត្រា ១៤.–**

គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ត្រូវធ្វើបញ្ជីរាយនាមបេក្ខជនពេញសិទ្ធិស្មើនឹងចំនួនអាសនៈនៃភូមិភាគនីមួយៗ និងបេក្ខជនបម្រុងមានចំនួនស្មើនឹងបេក្ខជនពេញសិទ្ធិរៀបតាមលំដាប់លេខរៀង ដូចជាការរៀបចំបញ្ជីបេក្ខជនតំណាងរាស្ត្រដែរ ។

**មាត្រា ១៥.–**

បទបញ្ជា និងនីតិវិធីទាំងឡាយ ស្ដីពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

# ជំពូកទី ៥

## ការឃោសនាបោះឆ្នោត

**មាត្រា ១៦.–**

ការឃោសនាបោះឆ្នោត មានទិសដៅឲ្យបេក្ខជន និងគណបក្សនយោបាយ ដែលបានចុះបញ្ជីធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនជូនដល់អ្នកបោះឆ្នោត ។

**មាត្រា ១៧.–**

ការឃោសនាបោះឆ្នោត ត្រូវធ្វើនៅតាមមណ្ឌលភូមិភាគនីមួយៗ ។

យុទ្ធនាការឃោសនាបោះឆ្នោត មានរយៈពេល ១៤ ( ដប់បួន ) ថ្ងៃ ហើយគ្រប់សកម្មភាពឃោសនាបោះឆ្នោតត្រូវចប់ ២៤ ( ម្ភៃបួន ) ម៉ោងមុនថ្ងៃបោះឆ្នោត ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា ១៨.-**

មាត្រា៦៨ ៦៩ ៧០ ៧១ កថាខ័ណ្ឌទី២ នៃមាត្រា៧២ មាត្រា៧៣ ៧៤ ៧៥ ៧៦ ៧៧ ៧៨ ៧៩ ៨០ ៨១ ៨២ ៨៣ ៨៤ ៨៥ ៨៦ ៨៧ ៨៨ ៨៩ ៩០ និងមាត្រា៩១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការឃោសនាបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ដោយឡែក ចំពោះការរៀបចំក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ នៅក្នុងមណ្ឌលភូមិភាគនីមួយៗ ត្រូវកំណត់យ៉ាងច្រើន ២ (ពីរ)ដង ក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។

## ជំពូកទី ៦

## ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត

**មាត្រា ១៩.-**

គណបក្សនយោបាយនីមួយៗ ដែលឈរឈ្មោះបោះឆ្នោតមានសិទ្ធិចាត់តាំងតំណាងរបស់ខ្លួន ២(ពីរ) រូប ពេញសិទ្ធិ ១(មួយ) រូប និងបម្រុង ១(មួយ) រូប ដើម្បីចូលរួមសង្កេតការណ៍មើលការបោះឆ្នោតតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ ។

សិទ្ធិ តួនាទី និងលក្ខខណ្ឌផ្សេងៗ ក្នុងការស្នើសុំជាភ្នាក់ងារគណបក្សនយោបាយ ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ២០.-**

មាត្រា១០ ១១ ១២ ១៣ ១៤ ១៥ ១៦ ១៧ ១៨ ១៩ ២០ ២១ និងមាត្រា២២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការសង្កេតការណ៍នៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

## ជំពូកទី ៧

## ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលនៃការបោះឆ្នោត

**មាត្រា ២១.-**

ការបោះឆ្នោតត្រូវធ្វើតែ ១(មួយ) ថ្ងៃ ។

ការបោះឆ្នោតប្រព្រឹត្តទៅចាប់ពីម៉ោង ៧:០០ ( ប្រាំពីរ )ព្រឹក រហូតដល់ម៉ោង ១៥:០០( ដប់ប្រាំ ) លើកលែងតែមានសេចក្តីសម្រេចផ្សេងពីនេះ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ប្រសិនបើអ្នកបោះឆ្នោតទាំងអស់ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត បានបោះគ្រប់គ្នាហើយ គណៈកម្មការិយាល័យបោះឆ្នោត អាចប្រកាសបញ្ចប់ការបោះឆ្នោតមុនម៉ោង ១៥ :០០ ( ដប់ប្រាំ ) ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវបិទការបោះឆ្នោតនៅម៉ោង ១៥ :០០ ( ដប់ប្រាំ ) ។

ជនគ្រប់រូបដែលមានបំណងបោះឆ្នោត មិនត្រូវអនុញ្ញាតឲ្យចូលក្នុងបរិវេណខាងក្នុងក្រោយម៉ោង១៥ :០០( ដប់ប្រាំ ) ឡើយ ។

ជនដែលមានសិទ្ធិបោះឆ្នោតក្រោយ ម៉ោង ១៥ :០០( ដប់ប្រាំ ) ហើយអាចអនុញ្ញាតឲ្យបោះឆ្នោត គឺជាជនដែលស្ថិតក្នុងការិយាល័យបោះឆ្នោត ឬក្នុងបរិវេណខាងក្នុងនៅម៉ោង ១៥ :០០ (ដប់ប្រាំ ) ។

**មាត្រា ២២.-**

គណៈកម្មការការិយាល័យបោះឆ្នោត ត្រូវទទួលខុសត្រូវរាប់សន្លឹកឆ្នោតនៅនឹងកន្លែង ក្រោយការប្រកាសបញ្ចប់ការបោះឆ្នោត ។

**មាត្រា ២៣.-**

គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ត្រូវបញ្ជូនកំណត់ហេតុសរុបលទ្ធផលនៃការបោះឆ្នោតនៅក្នុងរាជធានី ខេត្តរបស់ខ្លួន ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីបូកសរុបលទ្ធផលតាមភូមិភាគនីមួយៗ ។

**មាត្រា ២៤.-**

មាត្រាទាំងឡាយ ដែលមានចែងក្នុងជំពូកទី៨ អំពីការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត លើកលែងតែមាត្រា៩២ ១០៣ ១១៦ ១២៣ ១២៦ និងមាត្រា ១២៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងបទបញ្ញា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវយកមកអនុវត្តក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

## ជំពូកទី ៨

## សមត្ថកិច្ចដោះស្រាយករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោត

**មាត្រា ២៥.-**

គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ជាអ្នកសម្រេចដំបូងបង្អស់លើករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា លើកលែងករណីវិវាទកម្មទាំងឡាយ ដែលជាសមត្ថកិច្ចដំបូងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងក្រុមប្រឹក្សាធម្មនុញ្ញ ។

ក្នុងករណីមានបណ្តឹងជំទាស់ ឬតវ៉ានឹងសេចក្តីសម្រេចរបស់គណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសមត្ថកិច្ចពិនិត្យ និងសម្រេច ។

**មាត្រា ២៦.-**

ក្នុងករណីមានបណ្តឹងជំទាស់ ឬតវ៉ានឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចសម្រេចចុងក្រោយបិទផ្លូវតវ៉ា លើករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

**មាត្រា ២៧.–**

នីតិវិធីដោះស្រាយការវិវាទ ដែលមានចែងក្នុងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការដោះស្រាយករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោត ជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ការរាប់ចំនួនថ្ងៃគិត និងការសម្រេចលើបណ្ដឹងជំទាស់ ឬគិត ពុំត្រូវបានរាប់បញ្ចូលថ្ងៃបុណ្យជាផ្លូវការ ។

## ជំពូកទី ៦

## ការបាត់បង់អាសនៈនៃព្រឹទ្ធសភា និងការជ្រើសតាំងសមាជិកជំនួស

**មាត្រា ២៨.–**

មាត្រា១៣៨ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តចំពោះការបាត់បង់អាសនៈនៃព្រឹទ្ធសភា ។

**មាត្រា ២៩.–**

សមាជិកព្រឹទ្ធសភា ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ទៅតាមករណីណាមួយដូចខាងក្រោម ៖

-សាមីខ្លួនទទួលមរណភាព

-សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច

-សាមីខ្លួនសុំលាឈប់ជាលាយលក្ខណ៍អក្សរ ពីសមាជិកព្រឹទ្ធសភា

-សាមីខ្លួនត្រូវតុលាការផ្ដន្ទាទោសដាក់ពន្ធនាគារ ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ

-សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

កាលបើសមាជិកព្រឹទ្ធសភាណាមួយ ត្រូវបាត់បង់សមាជិកភាពមានរយៈពេល ០៦(ប្រាំមួយ) ខែ យ៉ាងតិចមុនចប់នីតិកាល ស្ថាប័នដែលមានអាសនៈនៅព្រឹទ្ធសភា ឬសាមីគណបក្សនយោបាយនោះ អាចស្នើចាត់តាំង ឬជ្រើសតាំងសមាជិកថ្មី ឬជ្រើសរើសក្នុងចំណោមបេក្ខជន ដែលមានឈ្មោះតាមលំដាប់លេខរៀងក្នុងបញ្ជីបេក្ខជនឈរឈ្មោះ បោះឆ្នោត នៃមណ្ឌលបោះឆ្នោតរបស់សាមីខ្លួននោះ មកជំនួសដោយមិនបាច់បោះឆ្នោតឡើងវិញ ។

## ជំពូកទី១០
## ទោសប្បញ្ញត្តិ

**មាត្រា ៣០.-**

ជំពូកស្តីពីទោសប្បញ្ញត្តិ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

## ជំពូកទី១១
## អវសានប្បញ្ញត្តិ

**មាត្រា ៣១.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ និងត្រូវជំនួសដោយច្បាប់នេះ ។

**មាត្រា ៣២.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០១៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

[illegible]

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ: ៥៤៧ ស.ណ
**សំ[illegible]ជាការចែកផ្សាយ**
រា[illegible] .ថ្ងៃ[illegible] ខែកក្កដា ឆ្នាំ២០១៧
[illegible]ការរាជរដ្ឋាភិបាល

**សយ សុខា**

នស/រកម/១០១៧/០១១

# ព្រះរាជក្រម

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៦ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ នាសម័យប្រជុំពេញអង្គលើកទី១១ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ១៩០/០៣០/២០១៧ កបធ.ដ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ច្បាប់
# ស្តីពី
# វិសោធនកម្មច្បាប់ស្តីពី
# ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

**មាត្រាមួយ..**

មាត្រា៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៦ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ៖

**មាត្រា ៣..ថ្មី**

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវធ្វើឡើង ០៦ (ប្រាំមួយ) ឆ្នាំម្តង នៅថ្ងៃអាទិត្យ សប្តាហ៍ទី ៤ យ៉ាងយូរ មុនដំណាច់ឆ្នាំទី ៦ នៃនីតិកាលព្រឹទ្ធសភា លើកលែងតែក្នុងករណីដែលមានចែងក្នុងបទប្បញ្ញត្តិមាត្រា ១០២ថ្មី នៃរដ្ឋធម្មនុញ្ញ ។

កាលបរិច្ឆេទនៃការបោះឆ្នោត ត្រូវកំណត់ និងប្រកាសដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

នីតិកាលព្រឹទ្ធសភា ត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។

**មាត្រាពីរ ..**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ២០១៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៧.១៧២០.៨៤៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ ៧៤៧ ស.ណ
**សំណៅដែលមានសិទ្ធិជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ តុលា ឆ្នាំ២០១៧
**... រាជរដ្ឋាភិបាល**

**សយ សុខា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

លេខ : ៣៤៣/០៨១/២០១៧

ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧

**សេចក្តីសម្រេច**

លេខ : ១៨៦/០២៦/២០១៧ កបធ.ច

ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៧

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុម-ប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែ មីនា ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញលិខិតលេខ ២១៦ ន.ស ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបាន

អនុម័តនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៨ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យនិងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់និងគតិច្បាប់ ដោយឥតកែប្រែក្នុងសម័យប្រជុំលើកទី១០ នីតិកាលទី៣ នាថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតខាងលើនេះនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ វេលាម៉ោង ១៦ និង ២០នាទី

**ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាគ្រប់គ្រាន់តាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភានិងព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យនិងអនុម័តច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- យល់ឃើញថា សំណើរបស់សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភាស្របតាមមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះ មកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែងនិងការអនុម័តច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ស្របនឹងរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី១ ស្ដីពី បទប្បញ្ញត្តិទូទៅ មាន ៣ មាត្រា គឺពីមាត្រា ១ ដល់មាត្រា ៣ ដែលចែងអំពីគោលដៅកំណត់ការរៀបចំបែបបទ និងការប្រព្រឹត្តទៅនៃការចាត់តាំង ការកំណត់អំពីអ្នកបោះឆ្នោត អង្គបោះឆ្នោត និងមណ្ឌលបោះឆ្នោត ការគ្រប់គ្រងការ-បោះឆ្នោត ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាត្រូវធ្វើឡើង ០៦ (ប្រាំមួយ) ឆ្នាំម្ដង កាលបរិច្ឆេទនៃការបោះឆ្នោតត្រូវកំណត់ និងប្រកាសដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ៣ នៃជំពូកទី១ នេះស្របតាមមាត្រា ១០១ថ្មី មាត្រា ១០២ថ្មី និង មាត្រា ១៥០ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី២ ស្ដីពីចំនួនសមាជិកព្រឹទ្ធសភា ប្រព័ន្ធបោះឆ្នោត មណ្ឌលបោះឆ្នោត និងការកំណត់ចំនួនអាសនៈ មាន ៦មាត្រា គឺពីមាត្រា ៤ ដល់មាត្រា ៩

ដែលចែងអំពីចំនួនសមាជិកព្រឹទ្ធសភា ស្ថាប័នចាត់តាំងនិងជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតត្រូវធ្វើឡើងដោយអសកល មិនចំពោះតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ការបោះឆ្នោតត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រ ការរៀបចំនិងបែងចែក មណ្ឌលបោះឆ្នោត និងការកំណត់ចំនួនអាសនៈនៅក្នុងព្រឹទ្ធសភា។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ៦ នៃជំពូកទី២ នេះ ស្របតាមមាត្រា ៩៩ថ្មី មាត្រា ១០០ថ្មី និងមាត្រា ១០១ថ្មី នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា ជំពូកទី៣ ស្តីពីអ្នកបោះឆ្នោត អង្គបោះឆ្នោត បញ្ជីបោះឆ្នោត និងការិយាល័យបោះឆ្នោត មាន ៣ មាត្រា គឺពីមាត្រា ១០ ដល់មាត្រា ១២ ដែលចែងអំពីអ្នកបោះឆ្នោត អង្គបោះឆ្នោត រយៈពេលនៃការរៀបចំបញ្ជីបោះឆ្នោត និងការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត លក្ខខណ្ឌនៃអ្នកមានសិទ្ធិបោះឆ្នោត និងការរៀបចំការិយាល័យបោះឆ្នោត។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ៣ នៃជំពូកទី៣ នេះ ស្របតាមមាត្រា ១០១ថ្មី និងមាត្រា ១៥០ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី៤ ស្តីពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ មាន ៣ មាត្រា គឺពីមាត្រា ១៣ ដល់មាត្រា ១៥ ដែលចែងអំពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ត្រូវអនុវត្តតាមមាត្រា ២៣ ដល់មាត្រា ៣៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ ការកំណត់អាយុរបស់បេក្ខជន បញ្ជីរាយនាមបេក្ខជនពេញសិទ្ធិ និងបម្រុង។ បទបញ្ជា និងនីតិវិធី ត្រូវកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ៣ នៃជំពូកទី៤ នេះ ស្របតាមមាត្រា ៣៤ថ្មី មាត្រា ១០១ថ្មី និងមាត្រា ១៥០ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី៥ ស្តីពីការឃោសនាបោះឆ្នោត មាន ៣ មាត្រា គឺពីមាត្រា ១៦ ដល់មាត្រា ១៨ ដែលចែងអំពីគោលបំណងនៃការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយ ទីកន្លែងនៃការឃោសនា។ យុទ្ធនាការឃោសនាមានរយៈពេល ១៤ (ដប់បួន)ថ្ងៃ ហើយគ្រប់សកម្មភាពឃោសនាបោះឆ្នោតត្រូវចប់ ២៤ (ម្ភៃបួន) ម៉ោងមុនថ្ងៃបោះឆ្នោត។ ការឃោសនាបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវអនុវត្តតាមមាត្រា ៦៨ ៦៩ ៧០ ៧១ កថាខ័ណ្ឌទី២ នៃមាត្រា ៧២ មាត្រា ៧៣ ៧៤

៧៥ ៧៦ ៧៧ ៧៨ ៧៩ ៨០ ៨១ ៨២ ៨៣ ៨៤ ៨៥ ៨៦ ៨៧ ៨៨ ៨៩ ៩០ និងមាត្រា ៩១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការហែក្បួនក្នុងមណ្ឌលភូមិភាគនីមួយៗអាចធ្វើបានយ៉ាងច្រើន ២ (ពីរ)ដង ក្នុងអំឡុងពេលឃោសនាបោះឆ្នោត។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ៣ នៃជំពូកទី៥ នេះ ស្របតាមមាត្រា ១០១ថ្មី និងមាត្រា ១៥០ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា ជំពូកទី៦ ស្តីពីភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត មាន ២ មាត្រា គឺមាត្រា១៩ និងមាត្រា២០ ដែលចែងអំពីគណបក្សនយោបាយនីមួយៗ ដែលឈរឈ្មោះបោះឆ្នោត មានសិទ្ធិចាត់តាំងតំណាងរបស់ខ្លួនដើម្បីចូលរួមសង្កេតការណ៍មើលការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតតាមការិយាល័យបោះឆ្នោតនីមួយៗ។ សិទ្ធិ តួនាទី និងលក្ខខណ្ឌផ្សេងៗក្នុងការស្នើសុំជាភ្នាក់ងារគណបក្សនយោបាយ ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ការសង្កេតការណ៍នៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវអនុវត្តតាមមាត្រា ១០ ដល់មាត្រា ២២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ២ នៃជំពូកទី៦ នេះ ស្របតាមមាត្រា ១០១ថ្មី និងមាត្រា ១៥០ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា ជំពូកទី៧ ស្តីពីការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត មាន ៤ មាត្រា គឺពីមាត្រា ២១ ដល់មាត្រា ២៤ ដែលចែងអំពីការបោះឆ្នោតត្រូវធ្វើតែ ១ (មួយ)ថ្ងៃ ចាប់ពីម៉ោង ៧:០០ (ប្រាំពីរ)ព្រឹក រហូតដល់ម៉ោង ១៥:០០(ដប់ប្រាំ) លើកលែងតែមានសេចក្តីសម្រេចផ្សេងពីនេះរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ គណៈកម្មការការិយាល័យបោះឆ្នោត ត្រូវរាប់សន្លឹកឆ្នោតនៅនឹងកន្លែង ក្រោយការប្រកាសបញ្ចប់ការបោះឆ្នោត។ គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតត្រូវបញ្ជូនកំណត់ហេតុសរុបលទ្ធផលនៃការបោះឆ្នោតនៅក្នុងរាជធានី ខេត្តរបស់ខ្លួនទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីបូកសរុបលទ្ធផលតាមភូមិភាគនីមួយៗ។ មាត្រាទាំងឡាយដែលមានចែងក្នុងជំពូកទី៨ អំពីការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត លើកលែងតែមាត្រា ៩២

១០៣ ១១៦ ១២៣ ១២៦ និងមាត្រា ១២៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងបទបញ្ញានិងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវយកមកអនុវត្តក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។បទប្បញ្ញត្តិក្នុងមាត្រាទាំង ៤ នៃជំពូកទី៧ នេះ ស្របតាមមាត្រា ១០១ថ្មី និងមាត្រា ១៥០ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា ជំពូកទី៨ ស្តីពីសមត្ថកិច្ចដោះស្រាយករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោត មាន ៣ មាត្រា គឺពីមាត្រា ២៥ ដល់មាត្រា ២៧ ដែលចែងអំពីសមត្ថកិច្ចក្នុងការសម្រេចលើករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងនីតិវិធីដោះស្រាយវិវាទដែលមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការដោះស្រាយករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ៣ នៃជំពូកទី៨ នេះ ស្របតាមមាត្រា ១០១ថ្មី កថាខ័ណ្ឌទី២ នៃមាត្រា ១៣៦ថ្មី និងមាត្រា ១៥០ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី៩ ស្តីពីការបាត់បង់អាសនៈនៃព្រឹទ្ធសភា និងការជ្រើសតាំងសមាជិកជំនួស មាន ២ មាត្រា គឺមាត្រា ២៨ និង មាត្រា ២៩ ដែលចែងអំពីការបោះបង់ចោលអាសនៈរបស់គណបក្សនយោបាយបន្ទាប់ពីការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ការបាត់បង់សមាជិកភាពជាសមាជិកព្រឹទ្ធសភា និងការចាត់តាំង ឬជ្រើសតាំង ឬជ្រើសរើសសមាជិកជំនួស។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ២ នៃជំពូកទី៩ នេះ ស្របតាមមាត្រា ១១៥ថ្មី និងមាត្រា ១៥០ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី១០ ស្តីពីទោសប្បញ្ញត្តិ មាន១ មាត្រា គឺមាត្រា ៣០ ដែលចែងអំពីជំពូកស្តីពីទោសប្បញ្ញត្តិនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ បទប្បញ្ញត្តិក្នុងមាត្រា ៣០ នៃជំពូកទី១០ នេះ ស្របតាមកថាខ័ណ្ឌទី២ នៃមាត្រា ៣១ កថាខ័ណ្ឌទី១ នៃមាត្រា ៤១ និងមាត្រា ៤៩ នៃរដ្ឋធម្មនុញ្ញ

-យល់ឃើញថា ជំពូកទី១១ ស្តីពីអវសានបញ្ញត្តិ មាន ២ មាត្រា គឺមាត្រា ៣១ និង មាត្រា ៣២ ដែលចែងអំពីបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ និងត្រូវជំនួសដោយច្បាប់នេះ។ ច្បាប់នេះត្រូវប្រកាសជាការប្រញាប់។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ២ នៃជំពូកទី១១ នេះស្របតាមមាត្រា ៩៣ថ្មី នៃរដ្ឋធម្មនុញ្ញ។

-យល់ឃើញថា ខ្លឹមសារទាំង ១១ ជំពូក ៣២ មាត្រា នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

**សម្រេច**

**មាត្រា ១.** ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៨ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែក្នុងសម័យប្រជុំ លើកទី១០ នីតិកាលទី៣ នាថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

**មាត្រា ២.** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៧ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៧

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**អ៊ឹម ឈុនលឹម**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ៣៤៧/០៨៥/២០១៧

ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧

**សេចក្តីសម្រេច**

លេខ : ១៩០/០៣០/២០១៧ កបធ.ច

ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សា-ធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៦ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានឃើញលិខិតលេខ ៣៨០ រ.ស. ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ របស់សម្តេចអគ្គ-មហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ នាសម័យប្រជុំលើកទី៩ នីតិកាលទី៥ និង

ព្រឹទ្ធសភា បានពិនិត្យនិងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥត កែប្រែ និងចាត់ទុកជាការប្រញាប់ ក្នុងសម័យប្រជុំលើកទី១១ នីតិកាលទី៣ នាថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលលិខិតខាង លើនេះ នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង ១១ និង ១០ នាទី

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបែបបទដែលមានចែងក្នុង មាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យនិងអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របតាមមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះ មកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និង ការអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការ បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ស្របនឹងរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា មាន ពីរមាត្រា និងមានខ្លឹមសារដូចខាងក្រោម÷

**មាត្រាមួយ** ..

មាត្រា ៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាដែលប្រកាសឱ្យ ប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៦ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ÷

មាត្រា ៣.. ថ្មី

**មាត្រាពីរ**.. ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់

- យល់ឃើញថា មាត្រាមួយនៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាខាងលើនេះ ត្រូវបានធ្វើវិសោធនកម្មពីរមាត្រាដូចខាងក្រោម ៖

  មាត្រា ៣.- ថ្មី ចែងអំពី "*ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវធ្វើឡើង ០៦ (ប្រាំមួយ) ឆ្នាំម្ដង នៅថ្ងៃអាទិត្យ សប្ដាហ៍ទី៤ យ៉ាងយូរ មុនដំណាច់ឆ្នាំទី៦ នៃនីតិកាលព្រឹទ្ធសភា លើកលែងតែក្នុងករណីដែលមានចែងក្នុងបទប្បញ្ញត្តិមាត្រា ១០២ ថ្មី នៃរដ្ឋធម្មនុញ្ញ ។*

  *កាលបរិច្ឆេទនៃការបោះឆ្នោត ត្រូវកំណត់ និងប្រកាសដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។*

  *នីតិកាលព្រឹទ្ធសភា ត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង។*"

  មាត្រានេះ ស្របតាមស្មារតីមាត្រា ១០១ ថ្មី និងមាត្រា ១០២ ថ្មី នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា មាត្រាមួយនៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា មាត្រាពីរ ដែលចែងថា ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ស្របតាមមាត្រា ៩៣ ថ្មី នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា គ្រប់បទប្បញ្ញត្តិទាំងអស់នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

## សម្រេច

**មាត្រា ១.-** ច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែ និងចាត់ទុកជាការប្រញាប់ ក្នុងសម័យប្រជុំលើកទី១១ នីតិកាលទី៣ នាថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

**មាត្រា ២.** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានី ភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**អ៊ឹម ឈុនលឹម**

បោះពុម្ពផ្សាយដោយ
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

វិមានរដ្ឋចំការមន, មហាវិថីព្រះនរោត្តម, ភ្នំពេញ
ទូរសោ: (៨៥៥-២៣) ២១១ ៤៤៦ / (៨៥៥-២៣) ២១១ ៤៤១
Email: oum_sarith@camnet.com.kh
Website : www.senate.gov.kh